# សេចក្តីប្រកាសអញ្ជើញចូលរួមដេញថ្លៃ

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា សូមជូនដំណឹងដល់ក្រុមហ៊ុនដែលបានចុះបញ្ជី ត្រឹមត្រូវ ឬអាជីវករដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានចំណាប់អារម្មណ៍លើអាជីវកម្មផ្ញើកង់ ម៉ូតូ និងរថយន្ត ឲ្យបានជ្រាបថាៈ វិទ្យាស្ថាន មានបំណង ដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសក្រុមហ៊ុន ឬអាជីវករធ្វើអាជីវកម្ម **ផ្ញើកង់ ម៉ូតូ និងរថយន្ត** សម្រាប់វិទ្យាស្ថានដែលមានទីតាំងស្ថិតនៅផ្លូវហាណូយ, សង្កាត់ឃ្មួញ, ខណ្ឌសែនសុខ, រាជធានីភ្នំពេញ លើផ្ទៃដីសរុបទំហំ ៧៥,៧៥០ ម៉ែត្រការ៉េ ក្នុងនោះផ្ទៃដី អាចផ្ញើកង់ ម៉ូតូ ចំនួន ៨១៣ គ្រឿង (ទំហំ ២,៦៥៥ ម៉ែត្រការ៉េ ) និង រថយន្តចំនួន ២០៨ គ្រឿង(ទំហំ ៥,៤២០ ម៉ែត្រការ៉េ) ។

ក្រុមហ៊ុន ឬអាជីវករ ដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញដាក់ពាក្យដេញថ្លៃ មក **លោក ហាស់ សម្បត្តិ ប្រធានការិយាល័យបុគ្គលិក និងរដ្ឋបាល** នៅអគារលេខ ៥០ ផ្លូវលេខ៥១៦ កែង៣៣៥ ភូមិ៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ត្រឹមថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង១២ ថ្ងៃត្រង់ ។

ឯកសារភ្ជាប់៖

- ពាក្យសុំចូលរួមដេញថ្លៃ ០១ច្បាប់
- លក្ខណៈបច្ចេកទេសគ្រប់គ្រង និងដំណើរការ ០១ច្បាប់
- ប័ណ្ណគ្រួសារថតចម្លង ចំនួន ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណថតចម្លង ០១ច្បាប់
- ព័ត៌មានសង្ខេប របស់អ្នកដេញថ្លៃ ចំនួន ០១ច្បាប់

លក្ខខណ្ឌ និងបន្ទុករបស់អ្នកដេញថ្លៃ៖

- ត្រូវបង់ប្រាក់កក់ធានាការដេញថ្លៃចំនួន ៤,០០០,០០០ ៛ (បួនលានរៀល) ចូលគណនីរបស់វិទ្យាស្ថាន ។ ក្រុមហ៊ុន ឬអាជីវករដេញថ្លៃមិនបានទទួលជោគជ័យ មានសិទ្ធិដកប្រាក់ធានាវិញ ។
- ការដេញថ្លៃចាប់ផ្តើមពី ១,៤០០,០០០ ៛ (មួយលានបួនរយពាន់រៀល) ក្នុង ០១ខែ
- អ្នកដេញថ្លៃទាំងអស់ ត្រូវចូលរួមដេញថ្លៃចំពោះមុខ គណៈកម្មការ នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ៨ ព្រឹក
- គម្លាតដេញថ្លៃម្តង ៤០,០០០ ៛ (សែសិបពាន់រៀល)
- តម្លៃសម្រាប់ផ្ញើកង់ ១០០ រៀល ម៉ូតូ ៣០០ រៀល និងរថយន្ត ១,០០០ រៀល
- មិនយកកម្រៃចំពោះយានយន្តគ្រប់ប្រភេទរបស់ បុគ្គលិក និងសាស្ត្រាចារ្យវិទ្យាស្ថាន
- សម្រាប់រយៈពេល ១ ឆ្នាំ ចាប់ពីខែ វិច្ឆិកា ឆ្នាំ២០១៨ ខែតុលា ឆ្នាំ២០១៩
- គោរពបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

ព័ត៌មានលម្អិត សូមទំនាក់ទំនងមក លោក ថាង ទី
ទូរស័ព្ទលេខ ០១៥ ៩០០ ១៨៩ E-mail: thang.ty@acledabank.com.kh

ថ្នាលអប់រំដើម្បីភាពជោគជ័យក្នុងអាជីព



# ពាក្យស្នើសុំចូលរួមដេញថ្លៃ ផ្ញើកង់ ម៉ូតូ និងរថយន្ត

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.........................................មុខរបរ  ឬមុខងារ.................................................................. ថ្ងៃខែឆ្នាំកំណើត..............................អត្តសញ្ញាណប័ណ្ណ លេខ:....................................... អាសយដ្ឋានបច្ចុប្បន្នៈ ផ្ទះលេខ ............ផ្លូវលេខ......................ឃុំ/សង្កាត់.....................................ស្រុក/ខណ្ឌ/ក្រុង.................................ខេត្ត/រាជធានី .................................ទូរស័ព្ទលេខ..............................................................................។

**សូមគោរពជូន**

**លោកប្រធានគណៈកម្មការគ្រប់គ្រង និងគាំទ្រដល់ដំណើរការរៀបចំអគារវិទ្យាស្ថាន**

**ការិយាល័យថ្មី**

**កម្មវត្ថុ** : **សំណើសុំចូលរួមដាក់ពាក្យដេញថ្លៃ ផ្ញើកង់ ម៉ូតូ និងរថយន្ត ជូនវិទ្យាស្ថាន**

**យោង** : សេចក្តីប្រកាសដេញថ្លៃ ផ្ញើកង់ ម៉ូតូ និងរថយន្ត នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមអនុញ្ញាតចូលរួមដេញថ្លៃ ផ្ញើកង់ ម៉ូតូ និងរថយន្តជូនវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

ខ្ញុំបាទ / នាងខ្ញុំ សូមសន្យាយ៉ាងម៉ឺងម៉ាត់ថា នឹងអនុវត្តតាមរាល់ប្រការដែលមានចែងក្នុងលក្ខខណ្ឌនៃការចូលរួមដេញថ្លៃ ដែលរៀបចំដោយ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ/នាងខ្ញុំ ។

ថ្ងៃ........ ខែ............. ឆ្នាំ......................... ព.ស..........

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ........ ឆ្នាំ...........

**ហត្ថលេខាអ្នកស្នើសុំ**

ឈ្មោះ.....................